00271328

C22/5/9

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ១៧) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់ អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 19 / 01 / 2009
ម៉ោង (Time/Heure): 10:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះចំពោះសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ**

---

**<u>អ្នកដាក់ឯកសារ៖</u>**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**<u>អ្នកទទួលឯកសារ៖</u>**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ធុល

ចៅក្រម ហ៊ួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## I. សេចក្ដីផ្ដើម

អនុលោមតាមសេចក្ដីបង្គាប់របស់អង្គបុរេជំនុំជម្រះ ចំពោះសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់បណ្ដឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ (ហៅថា "សេចក្ដីបង្គាប់")[1] តទៅនេះមេធាវីការពារស្នើសុំឱ្យមានសវនាការដេញដោលផ្ទាល់មាត់លើបណ្ដឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្នរបស់ ក.ស.ច.ស (ហៅថា "បណ្ដឹងឧទ្ធរណ៍")។

## II. អំណះអំណាងសង្ខេប

1. សវនាការដេញដោលផ្ទាល់មាត់ គឺចាំបាច់ចំពោះបណ្ដឹងឧទ្ធរណ៍នេះ ដោយសារតែ៖

ក. ការសន្មតជាមុនគឺផ្ដល់ប្រយោជន៍ឱ្យមានសវនាការដេញដោលផ្ទាល់មាត់ លើបណ្ដឹងឧទ្ធរណ៍ ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ហើយ សហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព") បានផ្ដល់អំណះអំណាងមិនគ្រប់គ្រាន់ ដើម្បីធ្វើយុត្តិកម្មលើការងាកចេញពីការសន្មតនេះនៅក្នុងបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន ។

ខ. ចាប់តាំងពីថ្ងៃដាក់បណ្ដឹងឧទ្ធរណ៍នេះ លោក **អៀង សារី** ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យជាច្រើនលើកច្រើនសារដែលបង្កឡើងដោយបញ្ហាសុខភាពដ៏រ៉ាំរ៉ៃរបស់គាត់ ដែលបញ្ហានេះជះឥទ្ធិពលដល់ការឃុំខ្លួនរបស់គាត់។ មានតែសវនាការដេញដោលផ្ទាល់មាត់ទេ នឹងអនុញ្ញាតយ៉ាងគ្រប់គ្រាន់ឱ្យមេធាវីការពារលើកឡើងនូវអំណះអំណាងថ្មីនេះ ហើយ ក.ស.ព ក៏អាចឆ្លើយតបបានយ៉ាងគ្រប់គ្រាន់ផងដែរ និង

គ. អំណះអំណាងដែលលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងចម្លើយតបរួមរបស់ពួកគេចំពោះបណ្ដឹងឧទ្ធរណ៍ ទាក់ទងនឹងការគំរាមកំហែងដល់សណ្ដាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯង ធានាឱ្យមានសវនាការជាសាធារណៈ។

---

[1] ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ១០) សេចក្ដីបង្គាប់ដល់ភាគីទាំងអស់ ចំពោះសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់បណ្ដឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី ១៤ មករា ២០០៩ ។

# III. ច្បាប់

2. វិធាន ៧៧(៣) នៃវិធានផ្ទៃក្នុង ចែងពីនីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍[2]ទៅអង្គបុរេជំនុំជម្រះ ដែលវិធាននេះចែងថា៖

(ក) ប្រធានអង្គបុរេជំនុំជម្រះត្រូវផ្ទៀងផ្ទាត់ថា សំណុំរឿងនោះមានភាពពេញលេញ និង កំណត់កាលបរិច្ឆេទនៃសវនាការ ។

(ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំ ដោយផ្អែកលើតែមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ ។

(គ) ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ភាគី និងមេធាវីរបស់ពួកគេ អំពីកាលបរិច្ឆេទនៃសវនាការ និង ការសម្រេចអំពីដំណើរការនីតិវិធី ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលដាក់ដោយភាគីតែប៉ុណ្ណោះ ។

3. ផ្តើមចេញពីវិធាននេះ វាហាក់ដូចជាថា ការសន្មតសម្រាប់បណ្តឹងឧទ្ធរណ៍ទាំងអស់ទៅអង្គបុរេជំនុំជម្រះ គឺថា វានឹងមានសវនាការដេញដោលផ្ទាល់មាត់មួយ ។ តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន អង្គបុរេជំនុំជម្រះអាចសម្រេចថា នៅពេលណាអញ្ញត្រកម្មទៅលើគោលការណ៍នេះ ត្រូវបានអនុញ្ញាត ។ គ្មានលក្ខណៈវិនិច្ឆ័យណាមួយមានចែងនៅក្នុងវិធានផ្ទៃក្នុងថា នៅពេលណាត្រូវងាកចេញពីការសន្មតអោយមានសវនាការដេញដោលផ្ទាល់មាត់មួយឡើយ។

4. មានបណ្តឹងឧទ្ធរណ៍ផ្សេងគ្នាៗមួយចំនួន ត្រូវបានសម្រេចដោយផ្អែកតែទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ដែលជាទូទៅ ដោយសារមានការព្រមព្រៀងរវាងភាគី ថាសវនាការដេញដោលផ្ទាល់មាត់[3]មិនចាំបាច់ឡើយ។ អង្គបុរេជំនុំជម្រះបានអនុញ្ញាតលើសំណើឲ្យមានសវនាការដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ដែលពុំមានការព្រមព្រៀងរវាងភាគី[4] ។

---

[2] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី២) ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ។

[3] ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ១០) សេចក្តីសម្រេចលើសំណើដើម្បីកំណត់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីការតែងតាំងអ្នកជំនាញការដោយផ្អែកតែលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ ២០០៨ ។

[4] ករណី ខៀវ សំផន សំណុំរឿងលេខ ០០២/១៩-៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ១១) សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន ស្នើសុំឲ្យមានសវនាការជាសាធារណៈ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

## IV. អំណះអំណាង

### ក. ក.ស.ព បានផ្តល់អំណះអំណាងមិនគ្រប់គ្រាន់ដើម្បីងាកចេញពីការសន្មតដែលនាំអោយមានសវនាការដេញដោលផ្ទាល់មាត់ឡើយ

5 ក.ស.ព អះអាងថា "ដើមបណ្តឹងឧទ្ធរណ៍មិនបានស្នើសុំឱ្យមានសវនាការដេញដោលផ្ទាល់មាត់ទៅលើបណ្តឹងឧទ្ធរណ៍នេះទេ"[5]។ ប៉ុន្តែ ក.ស.ព ព្រមទទួលយក ហើយក៏ត្រឹមត្រូវដែរ ថា "សវនាការសម្រេចលើការឃុំខ្លួនគួរត្រូវធ្វើឡើងដោយការដេញដោលដោយផ្ទាល់មាត់"[6]។ ជាលទ្ធផល គេសន្មតជាមុននូវសវនាការដេញដោលផ្ទាល់មាត់ ដូច្នេះវាគ្មានតម្រូវការអោយមេធាវីការពារត្រូវស្នើសុំឱ្យមានសវនាការបែបនេះឡើយ ។ ការអះអាងរបស់ ក.ស.ព ផ្ទុយពីនេះ គឺមិនត្រឹមត្រូវ ។

6 ចំពោះបញ្ហាថា តើមានមូលហេតុគ្រប់គ្រាន់ដែរឬទេ ដើម្បីងាកចេញពីការសន្មតនូវសវនាការដេញដោលផ្ទាល់មាត់នោះ ក.ស.ព គ្រាន់តែព្យាយាមកាត់បន្ថយសារៈសំខាន់របស់បណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ។ បើតាម ក.ស.ព "បណ្តឹងឧទ្ធរណ៍បច្ចុប្បន្នពាក់ព័ន្ធត្រឹមតែការបន្តថេរៈវេលានៃការឃុំខ្លួនដែលត្រូវបានសម្រេចរួចមកហើយនាពេលថ្មីៗនេះ ដូច្នេះហើយ មិនលេចឡើងនូវអំណះអំណាងខាងអង្គហេតុ និងអង្គច្បាប់ថ្មីដែលចាំបាច់ត្រូវធ្វើការថ្លែងប្រាស្រ័យនៅក្នុងសវនាការដេញដោលផ្ទាល់មាត់ឡើយ"[7] ។ ការអះអាងបែបនេះ មានតម្លៃតិចតួច ហើយគ្មានអ្វីក្រៅពីការប៉ុនប៉ងដោយមានការបិទបាំងតិចតួចដើម្បីកាត់បន្ថយសារៈសំខាន់នៃសេរីភាពរបស់លោក **អៀង សារី** ឡើយ។ថ្វីបើសាធារណៈមតិយល់ឃើញថាលោក **អៀង សារី** មានទោសរួចទៅហើយ ដូចដែលគេអាចមើលឃើញតាមរយៈអ្វីជាច្រើនដែល ក.ស.ព បានយកធ្វើជាមូលដ្ឋានសម្រាប់ការឃុំខ្លួនក៏ដោយ ក៏លោក **អៀង សារី** នៅតែបន្តទទួលបាននូវការសន្មត

---

[5] ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ១៧) ចម្លើយតបរបស់ ក.ស.ព ចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី៩ ខែ មករា ឆ្នាំ ២០០៩ កថាខណ្ឌ ៣ (ហៅថា "ចម្លើយតបរបស់ ក.ស.ព") ។

[6] ដូចខាងលើ (បញ្ជាក់បន្ថែម) ។

[7] ដូចខាងលើ ។

ជាមុនថាគ្មានទោសដដែល ។ អង្គបុរេជំនុំជម្រះមិនត្រូវធ្វើមិនដឹងមិនឮចំពោះសិទ្ធិជាមូលដ្ឋាននេះឡើយ ដោយគ្រាន់តែដោយសារ ក.ស.ព ស្នើសុំឲ្យធ្វើយ៉ាងដូច្នេះឡើយ ។

7 បណ្តឹងឧទ្ធរណ៍លើកឡើងពីទឡ្ហីករណ៍ខាងអង្គហេតុ និងអង្គច្បាប់ថ្មីៗ ដែលយ៉ាងសាមញ្ញបំផុតដាច់ខាតត្រូវតែពន្យល់ និងបកស្រាយជាលំអិត នៅក្នុងលក្ខណៈមួយដែលមានតម្លាភាពបំផុតតាមរយៈសេចក្តីសន្និដ្ឋានផ្ទាល់មាត់។ បើសិនជាដូចដែល ក.ស.ព បានអះអាងគឺថា បណ្តឹងឧទ្ធរណ៍នេះមិនលេចឡើងនូវទឡ្ហីករណ៍ខាងអង្គហេតុ និងអង្គច្បាប់ថ្មីៗនោះទេ នោះវាប្រាកដណាស់ថា ក.ស.ព មិនចាំបាច់ដាក់ចម្លើយតបដ៏ពិស្តារទៅនឹងបណ្តឹងឧទ្ធរណ៍នេះឡើយ មិនតែប៉ុណ្ណោះ ថែមទាំងមិនចាំបាច់ស្នើសុំពន្យារពេលបន្ថែមដើម្បីដាក់ចម្លើយតបដ៏ពិស្តារនោះដែរ។

**ខ. សវនាការដេញដោលផ្ទាល់មាត់តម្រូវអោយមានដើម្បីពិភាក្សាទៅលើព្រឹត្តិការណ៍ទាំងឡាយបន្ទាប់ពីការដាក់បណ្តឹងឧទ្ធរណ៍រួចមក**

8 ចាប់តាំងពីពេលប្តឹងឧទ្ធរណ៍កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ កន្លងមក លោក **អៀង សារី** ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យជាច្រើនលើកច្រើនសារ ដោយសារតែបញ្ហាសុខភាពធ្ងន់ធ្ងររបស់គាត់[8]។ មេធាវីការពារសូមលើកបញ្ហានេះនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយសារថាវាពិតជាមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើភាពសមស្របនៃការបន្តឃុំខ្លួនលោក **អៀង សារី**។ ប្រសិនបើបញ្ហានេះត្រូវបានលើកឡើងដោយផ្ទាល់មាត់ នោះវានឹងផ្តល់ដល់ ក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណីនូវឱកាសយ៉ាងគ្រប់គ្រាន់ដើម្បីឆ្លើយតប ជាពិសេស ខណៈដែលមេធាវីការពារបានផ្តល់ដំណឹងពីគោលបំណងរបស់ខ្លួនដែលចង់លើកឡើងនូវបញ្ហាទាំងនេះ នៅរយៈពេលយ៉ាងឆ្ងាយមុនពេលសវនាការដេញដោលផ្ទាល់មាត់។

9 សវនាការដេញដោលផ្ទាល់មាត់ ក៏នឹងមានប្រយោជន៍ដល់ផ្នែកថវិកាតុលាការផងដែរ។ សវនាការនេះនឹងអនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះទទួលបាន និងពិចារណាលើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ពីគ្រប់ភាគីទាំងអស់ ស្តីពីការវិវឌ្ឍន៍ទាំងនេះជាបន្តបន្ទាប់រហូតដល់ថ្ងៃសវនាការដេញដោល

[8] ចាប់តាំងពីពេលប្តឹងឧទ្ធរណ៍មក លោក **អៀង សារី** ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យចំនួនបីលើកដាច់ៗពីគ្នា។ លើកទីមួយ គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ជូនមកវិញនៅថ្ងៃបន្ទាប់។ លើកទីពីរ គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ជូនមកវិញនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០៩។ លើកទីបី គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០០៩ និង និងបញ្ជូនមកវិញនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩។

មាត់ ជំនួសអោយការចេញសេចក្តីសម្រេចមួយ ដែលយោងតែទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរ ដែលប្រហែលជាអាចមិនទាន់សភាពការណ៍[9]។

**គ. សវនាការដេញដោលផ្ទាល់មាត់តម្រូវអោយមាន ដោយសារតែអំណះអំណាងរុចអាលពីដើមបណ្តឹងរដ្ឋប្បវេណី**

10 សវនាការដេញដោលផ្ទាល់មាត់ទៅលើបណ្តឹងឧទ្ធរណ៍នេះតម្រូវអោយមាន ដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ទៅនឹងអំណះអំណាងរុកគួនខ្លះៗ ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសេចក្តីឆ្លើយតបរួមគ្នារបស់ខ្លួនចំពោះបណ្តឹងឧទ្ធរណ៍នេះ[10]។ ដើមបណ្តឹងរដ្ឋប្បវេណីសំអាងទៅលើទង្វើច្រងេងច្រងាង និង ប្រមាថជាទម្ងន់របស់ខ្លួនក្នុងការគំរាមកំហែងដល់មេធាវីការពារ **ខៀវ សំផន** ដើម្បីធ្វើយុត្តិកម្មបន្តឃុំខ្លួនលោក **អៀង សារី**[11]។ ទឡ្ហីករណ៍នេះត្រូវច្រានចោលជាសាធារណៈ នៅក្នុងទម្រង់មួយដែលភាគច្រើននៃដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំ នឹងបានដឹងលឺនូវការឆ្លើយតប ជាជាង សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដែលពិបាកនឹងទទួលដឹងលឺឆ្ងាយណាស់។

អាស្រ័យហេតុនេះ សម្រាប់មូលហេតុដែលបានលើកឡើងនៅចម្លើយតបនេះ មេធាវីការពារស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ៖

ក. **ច្រានចោល**សំណើរបស់ ក.ស.ព ដែលស្នើសុំឱ្យកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលក្ខណ៍អក្សរតែប៉ុណ្ណោះ និង

---

[9] យោងតាមអង្គបុរេជំនុំជម្រះ អង្គបុរេជំនុំជម្រះនឹងមានការប្រជុំមួយចាប់ពីថ្ងៃទី ២៣ ដល់ ២៧ ខែកុម្ភៈ ឆ្នាំ២០០៩។ ប្រសិនបើសវនាការដេញដោលផ្ទាល់មាត់ត្រូវបានធ្វើឡើងនៅក្នុងសប្តាហ៍នោះ សេចក្តីសន្និដ្ឋានថ្មីៗស្តីពីសុខភាពរបស់លោក **អៀង សារី** គិតមកត្រឹមថ្ងៃនោះនឹងត្រូវធ្វើឡើង ជាជាការតម្រូវឱ្យមានការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយតបរបស់ ក.ស.ព ដែលទំនងជានឹងត្រូវធ្វើក្នុងវេលាឆាប់ជាងនេះ។ *សូមមើល* អនុស្សារណៈអន្តរៈការិយាល័យស្តីពីកិច្ចប្រជុំរបស់អង្គបុរេជំនុំជម្រះសម្រាប់ពាក់កណ្តាលទីមួយនៃឆ្នាំ២០០៩ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ។

[10] រឿងក្តីរបស់ **អៀង សារី** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (ក.ស.ព១៧) សារណាឆ្លើយតបរួមគ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការបន្តរយៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ ("ចម្លើយតបរួមគ្នា")។

[11] ចម្លើយតបរួមគ្នា កថាខណ្ឌ ២៥។

C22/5/9

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ១៧)

ខ. កំណត់កាលបរិច្ឆេទសវនាការដេញដោលផ្ទាល់មាត់ទៅលើបណ្តឹងឧទ្ធរណ៍ នៅចន្លោះពីថ្ងៃទី២៣ ដល់ ២៧ ខែកុម្ភៈ ឆ្នាំ២០០៩។

យើងខ្ញុំសូមដាក់ជូននូវចម្លើយតបនេះដោយសេចក្តីគោរព។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩

............................ ............................

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី